# រាជរដ្ឋាភិបាលកំពុងធ្វើការខាងលើចំណែករបស់ខ្លួនសំរាប់ការកាត់ទោសខ្មែរក្រហម

**Government is Doing Its Part For KR Tribunal**

( ដោយ Dr. Helen Jarvis, ទីប្រឹក្សានៃក្រុមការងារជំនុំជំម្រះក្តីខ្មែរក្រហម ។ ដកស្រង់ចេញពី The Cambodia Daily ចុះថ្ងៃទី ១៧ តុលា ឆ្នាំ ២០០៥ )

ការធ្វើវិភាគទានថ្មី១ចំនួន១លានដុល្លារពីប្រទេសឥណ្ឌាចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវបានទទួលស្វាគមន៍ និងពេញចិត្តយ៉ាងជ្រៅលជ្រៅ ពីសំណាក់ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានរាយការណ៍នៅក្នុងអត្ថបទរបស់លោក : " ប្រទេសឥណ្ឌាសន្យាផ្តល់ប្រាក់ ១ លានដុល្លារសំរាប់តុលាការខ្មែរក្រហម "។ ( ទំព័រ ១ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ )

ទាក់ទិនទៅនិងការធ្វើវិភាគទានរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះអង្គជំនុំជម្រះវិសាមញ្ញ អត្ថបទនោះបានសរសេរថា : " រដ្ឋាភិបាលត្រូវទទួលរ៉ាប់រងលើទឹកប្រាក់ដែលនៅខ្វះចំនួន ១៣.៣ លានដុល្លារ ក៏ប៉ុន្តែនៅខែមិនាកន្លងទៅ រាជរដ្ឋាភិបាលបានប្រកាសថាខ្លួនមានលទ្ធភាពចូលរួមវិភាគទានត្រឹមតែ ១.៥ លានដុល្លារប៉ុណ្ណោះ "។ **នេះជាការមិនត្រឹមត្រូវទេ ។**

កាលពីខែធ្នូ ឆ្នាំ ២០០៣ បេសកម្មជំនួយបច្ចេកទេសរបស់អង្គការសហប្រជាជាតិ បានស្នើអោយមានការបែងចែកថវិកាដែលមួយចំណែកត្រូវស្វែងរកដោយវិភាគទានពហុភាគី តាមរយៈអង្គការសហប្រជាជាតិ ( ៤៣ លានដុល្លារ ) និងមួយចំណែកទៀតដែលនៅសល់ នឹងត្រូវស្វែងរកដោយរាជរដ្ឋាភិបាលកម្ពុជា ( ១៣.៣ លានដុល្លារ) ។

តាំងពីពេលដំបូងបំផុត រាជរដ្ឋាភិបាលលម្ពុជាបានបង្ហាញច្បាស់ថា ខ្លួនពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីរ៉ាប់រងនូវចំនួនថវិកាទាំងមូលនៃចំណែករបស់ភាគីកម្ពុជាទេ ហើយនឹងស្វែងរកវិភាគទានទ្វេភាគី ។ គឺមិនមែនជាការផ្លាស់ប្តូរនូវការប្តេជ្ញាចិត្តដែលខ្លួនបានធ្វើកាលពីមុននោះឡើយ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវអោយមានការធ្វើវិភាគទានទ្វេភាគី ហើយបានសន្យាថានឹងធ្វើវិភាគទានចំនួនទឹកប្រាក់ ១.៥ លានដុល្លារពីថវិកាជាតិរបស់ខ្លួននោះ ។

បន្ថែមទៅលើចំនួនសាច់ប្រាក់នេះកម្ពុជានឹងរ៉ាប់រងលើចំណាយដោយប្រយោលចំនួន ៥.២ លានដុល្លារទៀត ក្នុងនោះរួមមានការផ្តល់នូវទីតាំងអាគារសំរាប់តុលាការ ទឹក អគ្គិសនី សាងសង់ និងគ្រប់គ្រងមន្ទីរឃុំឃាំង សេវាកម្មពេទ្យ និងការរៀបចំសន្តិសុខ ដែលទាំងអស់នេះមិនត្រូវបានរាប់បញ្ចូលនៅក្នុងថវិកាចំនួន ១៣.៣ លានដុល្លារ ផងទេ ។

ដូចនេះការធ្វើវិភាគទានសរុបរបស់ភាគីកម្ពុជាចំនួន ៦.៧ លានដុល្លារគិតទាំងសាច់ប្រាក់សុទ្ធ និងការចំណាយដោយប្រយោលលើសពី ១០% នៃចំនួនទឹកប្រាក់សរុបសំរាប់ដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ហើយជាចំនួនទឹកប្រាក់ដែលសមល្មម និងលើសពីវិភាគទានរបស់សាមីប្រទេសចំពោះតុលាការ ចំរុះ ឬតុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតផងដែរ ។